# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៩៩ រប-៩៦

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**សូមជម្រាបមក**

-លោកប្រធានតុលាការកំពូល
-លោកអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
-លោកចាងហ្វាងសាលាឧទ្ធរណ៍
-លោកអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
-លោកប្រធានតុលាការខេត្ត ក្រុង
-លោកព្រះរាជអជ្ញាអមតុលាការខេត្ត ក្រុង

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការបង្រ្កាបអំពើរំលោភច្បាប់ ។

ក្នុងឱកាសបញ្ចប់សន្និបាតប្រចាំឆ្នាំ នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៥ ខ្ញុំបានជម្រាបអស់លោកអំពីការលំបាកបង្កឡើងអោយយើងពីការរំលោភច្បាប់ ពីសំណាក់អ្នកមានសិទ្ធិអំណាច ឬមានកម្លាំងអាវុធនៅដៃ ឬមានអ្នកការពារនៅពីក្រោយខ្នងហើយខ្ញុំបានសុំអោយយើងទាំងអស់គ្នាប្តូរផ្តាច់ជាមួយគ្នា ដើម្បីបំបាត់អំពើទាំងនេះអោយអស់ពីមួយជំហានទៅមួយជំហាន នៅក្នុងឆ្នាំថ្មី ១៩៩៦ នេះ ។

ខ្ញុំមានសេចក្តីរីករាយជាអតិបរមាជម្រាបអស់លោកជ្រាបថា ករណីអនុវត្តសាលក្រម១របស់តុលាការក្រុងភ្នំពេញមិនបានសម្រេចជាលើកទី៣ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៥ ដោយមានការរារាំងពីក្រុមប្រដាប់អាវុធ១ក្រុមនៅការពារផ្ទះកើតហេតុហើយកម្លាំងទាំងនគរបាល ទាំងយោធា ដែលទៅចូលជាកម្លាំងជួយអនុវត្តសាលក្រមនោះត្រូវបានមេបញ្ជាការរបស់គេបញ្ជាពីលើអោយដកថយទៅវិញអស់នោះ ការអនុវត្តសាលក្រមនេះត្រូវបានសម្រេចជាស្ថាពរនៅពេលចុះអនុវត្តជាលើកទី៤, នៅថ្ងៃទី១១ ខែមករា ឆ្នាំ១៩៩៦ ដោយមានការពុះពារស្វិតស្វាញពីក្រសួងយុត្តិធម៌ ។

ការអនុវត្តបាននេះ ដោយខ្នងធំៗរបស់ភាគីចាញ់ក្តីលែងហ៊ានការពារទៀតបានលើកឥទ្ធិពលរបស់តុលាការធំណាស់។ ខ្ញុំជឿជាក់ថាចាប់ពីថ្ងៃនេះតទៅនៅក្រុងភ្នំពេញការអនុវត្តសាលក្រមប្រាកដជាលែងជួបបញ្ហាធំដុំទៀតហើយ ។

ករណីមួយទៀតដែលខ្ញុំបានជម្រាបអស់លោកដែរ គឺករណីបាតុកម្មហឹង្សាដង្ហែរក្បួនទៅវាយតុលាការខេត្តកំពត ដោយពុទ្ធបរិស័ទជើងវត្ត និងព្រះសង្ឃវត្តឧទម្ពុ ស្រុកកំពង់ត្រាច ខេត្តកំពត មានកម្លាំងជារូបចំនួន ២០០ នាក់មានអាវុធជាកាំបិត ពូថៅ ដំបង ប្រេងម៉ាស៊ីនលាយទឹកអាស៊ីតនៅដៃ ។

ការវាយកំទេចមន្ទីរតុលាការនេះ បានបំផ្លាញឥទ្ធិពលរបស់តុលាការកំពត និងកិត្តិយសរបស់មន្ត្រីតុលាការគួរអោយឈឺចាប់ខ្លាំង ។

ក្រសួងយុត្តិធម៌បានសរសេរលិខិតទៅក្រសួងមហាផ្ទៃ ដូចបានចម្លងជូនអស់លោកជ្រាបផងដែររួចហើយ ហើយបានបញ្ជាទៅព្រះរាជអាជ្ញាឱ្យធ្វើការចោទប្រកាន់លើជនញុះញង់ លើជនដៃដល់ និងលើជនសមគំនិតដាក់ជូនតុលាការផ្តន្ទាទោស ការធ្វើយ៉ាងនេះ គឺដើម្បីស្តារឥទ្ធិពលរបស់តុលាការឡើងវិញ ។

ករណីដែលនៅសល់ ក្នុងចំណោមករណីដែលខ្ញុំបានជម្រាបអស់លោកនៅថ្ងៃបញ្ចប់សន្និបាតការងារយុត្តិធម៌ យើងនោះគឺករណីយោធាខេត្តក្រចេះ និងករណីយោធាខេត្តកោះកុង ក្រសួងយុត្តិធម៌នឹងខំពុះពារស្វិតស្វាញឱ្យទាល់តែដោះស្រាយបញ្ហាពីរនេះបាននៅពេលឆាប់ៗខាងមុខនេះ ។

អ្វីដែលយើងសម្រេចបានដូចខ្ញុំបានជម្រាបជូនខាងលើនេះ ជាការលើកទឹកចិត្តមួយធំចំពោះមន្ត្រីតុលាការអយ្យការយើង ។ ខ្ញុំសូមអស់លោកប្តូរផ្តាច់រៀងៗខ្លួន ដើម្បីបោសសំអាតអោយអស់គ្រប់អំពើរំលោភច្បាប់ ដែលកើតមានឡើងនៅក្នុងខេត្ត-ក្រុង រៀងៗខ្លួនរបស់អស់លោកដើម្បីយើងឈានទៅដល់ទីនៅចុងក្រោយរបស់យើង គឺឱ្យព្រះរាជាណាចក្រកម្ពុជាទៅជានីតិរដ្ឋ ។

ខ្ញុំសូមបញ្ជាក់ជូនអស់លោកថា ក្រសួងយុត្តិធម៌នៅពីក្រោយអស់លោកជានិច្ច ហើយការពារអស់លោកគ្រប់ពេលវេលា ដរាបណាអស់លោកបំពេញភារកិច្ចរបស់អស់លោកត្រឹមត្រូវតាមច្បាប់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**